មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-១១-២០០៦-ព្រះរាជក្រឹត្យនស/រកត/១១០៦/៤៤៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ចំពោះ ឯកឧត្តម លោក លោកស្រី ចំនួន ០៩ រូប ៧៣៧៣

II~ក្រុមប្រឹក្សាធម្មនុញ្ញ

១០-១១-២០០៦ -សេចក្តីសម្រេចលេខ ០៨២/០០៩/២០០៦ កបធ.ច ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០០៦ ៧៣៧៤

III~រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៣-១១-២០០៦ -អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពីការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារ ជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី ៧៣៧៦

១៣-១១-២០០៦ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពីការទទួលស្គាល់វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ៧៣៨២

១៣-១១-២០០៦ -អនុក្រឹត្យលេខ ៧០៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣៨៤

១៣-១១-២០០៦ -អនុក្រឹត្យលេខ ៧០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៨៨

១៣-១១-២០០៦ -អនុក្រឹត្យលេខ ៧១០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣៩០

១៣-១១-២០០៦ -អនុក្រឹត្យលេខ ៧១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៩២

១៣-១១-២០០៦ -អនុក្រឹត្យលេខ ៧១២ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចជូនមន្ត្រីរាជការ ៧៣៩៤

១៤-១១-២០០៦ -អនុក្រឹត្យលេខ ៧១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៩៥

IV~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៣-១១-២០០៦ -ប្រកាសណែនាំលេខ ១១៣២ សហវ ស្តីពីការបិទបញ្ជីចំណូល-ចំណាយ និងការធ្វើរបាយការណ៍ បូកសរុបទូទាត់ចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៦ ៧៣៩៦

១៤-១១-២០០៦ -ប្រកាសលេខ ១១៤៦ សហវ.ប្រក ស្តីពីការបង្កើតគណៈកម្មការដឹកនាំគំរោងស្វ័យប្រវត្តិកម្មការងារគយ ៧៤០៧

១៤-១១-២០០៦ -ប្រកាសលេខ១១៤៧ សហវ.ប្រក ស្តីពីការបង្កើតក្រុមការងារគំរោងជាតិនិងក្រុមផ្តល់ប្រឹក្សាបច្ចេកទេសលើការងារស្វ័យប្រវត្តិកម្មគយ ៧៤១០

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជាន អ៊ុំ-លែន** ៧៤១៣

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អេស.ស៊ី.អេ** ៧៤១៥

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វារ អ៊ីស្ត មេឌីខល (ខេមបូឌា) លីមីធីត** ៧៤១៧

១៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រស្មី សំបូរផល ខនស្ត្រាក់សិន** ៧៤១៩

១៨-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពន្លឺ សន្តិភាព ខនស្ត្រាក់សិន** ៧៤២១

១៩-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤២១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខារហ្គោដត (ខេមបូឌា)** ៧៤២៣

១៩-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឱរ៉ាល់ គ្រុប** ៧៤២៥

១៩-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គុយ លាងគី ខនស្ត្រាក់សិន ត្រេឌីង គ្រុប ខូ អិលធីឌី** ៧៤២៧

១៩-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គី.គី.យូ. (ខេមបូឌា) អ៊ឹមផត អិចផត** ៧៤២៩

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លី ឌីសាញ អិជីនារីង (ខេមបូឌា)** ៧៤៣១

២៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២៤៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេនជេឡា រឿល អ៊ីស្តេត** ៧៤៣៣

នស/រកត/១០០៦/៤៤៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម តេង សាវង្ស

២-ឯកឧត្តម ឈួ វ៉ាមីន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

-ឯកឧត្តម កៅ ខុនជាវ៉ា

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១-លោក ហ៊ុន សុធី

២-លោកស្រី អ៊ុំ ស្រ៊ី

៣-លោក គន ប៉ូរ៉ាមី

៤-លោក ស នារិទ្ធ

៥-លោក ញៀម សុខារ័ត្ន

៦-លោក មាស រិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៤២១ ច.ល

៣៧៩.០៦១១.៤៧៣

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦

អគ្គលេខាធិការគណៈរដ្ឋមន្ត្រី
ស៊ុន ចាន់ថុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង
លេខ : ១១១/០១១/២០០៦
ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៦

សេចក្តីសម្រេច
លេខ : ០៨២/០០៩/២០០៦ កបធ.ច
ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- បានឃើញលិខិតលេខ តរ.ករម.៣០/០៦ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់ឯកឧត្តម លោកជំទាវតំណាងរាស្ត្រ ចំនួន ១៦ រូប ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ០៩ : ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់ឯកឧត្តម និង លោកជំទាវតំណាងរាស្ត្រ ចំនួន ១៦រូប ស្របតាមលក្ខខណ្ឌនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ។

- យល់ឃើញថា អភ័យឯកសិទ្ធិសភាត្រូវបានផ្តល់ជូនរដ្ឋសភា ។
- យល់ឃើញថា តំណាងរាស្ត្រគ្រប់រូបមានអភ័យឯកសិទ្ធិសភា ដែលធានាមិនឱ្យតំណាងរាស្ត្របារម្ភអំពីការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ឬ អំណាចតុលាការ ។ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ក៏មានព្រំដែនកំណត់ដែរ ។
- យល់ឃើញថា មាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មានខ្លឹមសារគ្រើនរំឭកដល់តំណាងរាស្ត្រ ហើយពុំមានធ្វើឱ្យតំណាងរាស្ត្របាត់បង់អភ័យឯកសិទ្ធិសភារបស់ខ្លួនឡើយ។

សម្រេច

មាត្រា ១.- ផ្អែកតាមមូលបទខាងលើ មាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ពុំមានអធម្មនុញ្ញភាពទេ ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ទិព ណើន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៩.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុល ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជាយស្វ័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងតភ្ជាប់ផ្លូវដែកសិង្ហបុរី-គុនមីញ
- យោងតាមលិខិតគោលនយោបាយដែលបានដាក់ជូនធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៦ និងអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីគម្រោងស្តារជួសជុលឡើងវិញផ្លូវដែកនៅកម្ពុជា ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦

ស ម្រេ ច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

បង្កើតគណកម្មាធិការតម្រង់ទិសសម្រាប់ និងក្រុមការងារសម្រាប់អនុវត្តគម្រោងជួសជុលស្តារផ្លូវដែកកម្ពុជាឡើងវិញ ដោយឥណទានថវិកាកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រុមការងារនេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ហើយត្រូវមានបុគ្គលិក វចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់ខ្លួន ស្របទៅតាមគោលការណ៍ដែលបានឯកភាពជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ។

ជំពូកទី ២
សមាសភាព

មាត្រា ២.-

សមាសភាពនៃគណៈកម្មាធិការតម្រង់ទិស ត្រូវបានយកសមាសភាពក្នុងមាត្រា ២ ជំពូកទី ២ នៃអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគម្រោងតភ្ជាប់ផ្លូវដែកសិង្ហបុរី-គុនមីញ។

មាត្រា ៣.-

បង្កើតក្រុមការងារគ្រប់គ្រងសម្បទាន នៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីគ្រប់គ្រងការងារលទ្ធកម្មសម្បទាន និងទំនាក់ទំនងរវាងក្រុមហ៊ុនប្រតិបត្តិកររាជាយស្វ័យយានក្នុងអាណត្តិសម្បទាន។ ក្រុមការងារគ្រប់គ្រងសម្បទានត្រូវរាយការណ៍ជូន និងទទួលខុសត្រូវលើការងាររបស់ខ្លួនចំពោះមុខរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរាជរដ្ឋាភិបាល។ សមាជិកទាំងអស់ត្រូវបំពេញការងារដោយឯករាជ្យ អព្យាក្រឹត្យ និងរក្សាការសម្ងាត់ ដោយមិនចាំបាច់ស្វែងរក ឬ ទទួលការណែនាំពីខាងក្រៅលើការងាររបស់ខ្លួនឡើយ។ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិអញ្ជើញបុគ្គលដែលមានការពាក់ព័ន្ធដើម្បីផ្តល់ព័ត៌មាន ឬយោបល់ដល់ក្រុមការងារគ្រប់គ្រងសម្បទានតាមការចាំបាច់។ ក្រុមការងារគ្រប់គ្រងសម្បទាន មានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម អ៊ុក ចាន់ រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន

២- ឯកឧត្តម **ទន្សី ទិសុវ្យត**	អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៣- ឯកឧត្តម **ជា ច័ាន់ដេត**	នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៤- ឯកឧត្តម **ស៊ុយ សាន**	អគ្គាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
៥- លោក **តឹកវ៉ែត សំរេច**	ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៦- លោក **ចាន់ សុធី**	ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧- តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន ០១រូប		សមាជិក

មាត្រា ៤.-

បង្កើតក្រុមការងារអនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ហើយក្រុមការងារនេះត្រូវរាយការណ៍ និងទទួលខុសត្រូវលើការគ្រប់គ្រង និងដឹកនាំការងាររបស់ខ្លួន ចំពោះមុខរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដែលជាអ្នកកំណត់ទិសដៅកិច្ចការរដ្ឋបាលសម្រាប់សមាជិកក្រុមការងារអនុវត្តគម្រោង ហើយសមាជិកទាំងអស់ត្រូវបំពេញការងារដោយឯករាជ្យ អព្យាក្រឹត្យ និងរក្សាការសម្ងាត់ ដោយមិនចាំបាច់ស្វែងរក ឬទទួលការណែនាំពីខាងក្រៅ លើសេចក្តីសម្រេចកិច្ចការរដ្ឋបាលរបស់ខ្លួនឡើយ។ ក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តគម្រោងមានសមាសភាព ដូចខាងក្រោម :

១- លោក **យិត បុណ្ណា**	នាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស	នាយកគម្រោង
២- លោក **លី បូរិន**	នាយកផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា	ប្រធានគ្រប់គ្រងបច្ចេកទេស
៣- លោក **ចាន់ សំឡេង**	នាយក ផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា	ប្រធានគ្រប់គ្រងទូទៅ
៤- លោក **ឡៃ ម៉ុនតីក**	ប្រធានបណ្តាញផ្លូវដែកពាយ័ព្យទិស រាជាយស្វ័យយានកម្ពុជា	ទទួលបន្ទុកបណ្តាញផ្លូវដែក (ភ្នំពេញ-ប៉ោយប៉ែត)
៥- លោក **ម៉េង លី**	ប្រធានទទួលបន្ទុកសិល្បការ្យ និងស្ថាបនាថ្មី រាជាយស្វ័យយានកម្ពុជា	(ភ្នំពេញ-ក្រុងព្រះសីហនុ)

៦-	លោក **អ៊ិត សាំងសុផល**	មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងសាធារណការ និងដឹកជញ្ជូន	ទទួលបន្ទុកលទ្ធកម្ម-គណនេយ្យ
៧-	លោក **នឹង ម៉ារីណា**	មន្ត្រីនៃមជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងសាធារណការ និងដឹកជញ្ជូន	ទទួលបន្ទុករដ្ឋបាល
៨-	លោក **វតន៍ សាម៉ន**	មន្ត្រីខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន	ជំនួយការរដ្ឋបាល

មាត្រា ៥.-

បង្កើតក្រុមការងារសម្រាប់អភិវឌ្ឍដីធ្លីអោយទទួលខុសត្រូវក្នុងការអភិវឌ្ឍដីធ្លីជាអចលនទ្រព្យរបស់រាជាយស្វ័យយានកម្ពុជា តាមរយៈការជួល ប៉ុន្តែមិនអាចផ្ទេរ ឬ លក់ដីទាំងនោះចេញពីកម្មសិទ្ធិរដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈរាជាយស្វ័យយានកម្ពុជា។ ការអភិវឌ្ឍដីធ្លីនេះ មានគោលបំណងប្រមូលយកប្រាក់ចំណូលសុទ្ធដែលបានពីការអភិវឌ្ឍ ដើម្បីទូទាត់ថ្លៃចំណាយបន្ថែមដែលមិនបានគ្រោងទុក និងប្រើជាដើមទុនសម្រាប់ការសាងសង់បណ្តាញផ្លូវដែកនាពេលអនាគត។ ក្រុមការងារសម្រាប់អភិវឌ្ឍដីធ្លី មានសមាសភាពដូចខាងក្រោមនេះ:

១-	ឯកឧត្តម **សុខុម តគចន្ធមុនី**	ប្រធានអគ្គនាយករាជាយស្វ័យយានកម្ពុជា	ប្រធាន
២-	តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី		សមាជិក
៣-	តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន		សមាជិក
៤-	តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ		សមាជិក
៥-	តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់		សមាជិក
៦-	លោក **ស៊ូ ផល្លី**	នាយករងរដ្ឋបាល រាជាយស្វ័យយានកម្ពុជា	សមាជិក
៧-	លោក **នៅ ឌីណា**	បុគ្គលិករាជាយស្វ័យយានកម្ពុជា	សមាជិកអចិន្ត្រៃយ៍

ជំពូកទី ៣
តួនាទី និងភារកិច្ច

មាត្រា ៦.-

គណៈកម្មាធិការតម្រង់ទិសគម្រោងមានភារកិច្ច ពិនិត្យ សម្របសម្រួល និងផ្តល់អនុសាសន៍ទាក់ទងនឹងការអនុវត្តគម្រោង តាមស្មារតីនៃអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦។



មាត្រា ៧.-

ក្រុមការងារគ្រប់គ្រងសម្បទាន មានភារកិច្ចពិនិត្យ និងវាយតម្លៃលើឯកសារលទ្ធកម្ម ដើម្បីផ្ដល់សម្បទានដល់ប្រតិបត្តិករដែលជាក្រុមហ៊ុនឯកជនធ្វើអាជីវកម្មលើបណ្ដាញផ្លូវដែកកម្ពុជា ដែលបានស្ដារ ជួសជុលរួចក្រោមគម្រោងនេះ និងដំណើរការការងាររបស់ខ្លួនដោយអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព គណនេយ្យភាព និងធ្វើការតាមដានត្រួតពិនិត្យកិច្ចសន្យាសម្បទាន និងការគោរពតាមលក្ខខ័ណ្ឌសុខភាព សុវត្ថិភាពពលកម្ម និងបរិស្ថានរបស់ប្រតិបត្តិករ ហើយធ្វើរបាយការណ៍ពីសកម្មភាពរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីពិនិត្យ និងធ្វើការងារតាមសមត្ថកិច្ច។

មាត្រា ៨.-

ក្រុមការងារសម្រាប់អនុវត្តគម្រោង មានភារកិច្ចអនុវត្ត និងគ្រប់គ្រងការអនុវត្តគម្រោង រាប់បញ្ចូលទាំងការងារលទ្ធកម្ម សាងសង់ និងការដកប្រាក់កម្ចី និងធ្វើរបាយការណ៍សកម្មភាពរបស់ខ្លួនជូនធនាគារអភិវឌ្ឍន៍អាស៊ី និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព និងគណនេយ្យភាព ហើយអនុលោមតាមល័ក្ខខ័ណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦។

មាត្រា ៩.-

ក្រុមការងារអភិវឌ្ឍន៍ដីធ្លី មានភារកិច្ចធ្វើការអភិវឌ្ឍអចលនទ្រព្យរបស់រាជាយស្ម័យយានកម្ពុជា សម្រាប់បម្រើគោលបំណង និងគោលដៅ ដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ និងដំណើរការការងាររបស់ខ្លួន ដោយអនុលោមទៅតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព និងគណនេយ្យភាព និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគ្រាសសាធារណៈរាជាយស្ម័យយានកម្ពុជា។

ជំពូកទី ៤
អន្តរប្បញ្ញត្តិ

មាត្រា ១០.-

គណៈកម្មាធិការតម្រង់ទិសគម្រោង ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។

មាត្រា ១១.-

អង្គភាពគ្រប់គ្រងសម្បទាន និងក្រុមការងារអនុវត្តន៍គម្រោង ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

មាត្រា ១២.-

ក្រុមការងារអភិវឌ្ឍន៍ដីធ្លី ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រាជាផ្លូវការរបស់រាជាយស្វ័យយានកម្ពុជា។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា ១៣.-

អនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់អនុវត្តគម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួង អប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១ : ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថាន អប់រំ ពាណិជ្ជសាស្ត្រ Institute for Business Education ហៅកាត់ជាភាសាខ្មែរ "វ.អ.ព" និងហៅកាត់ជាភាសាអង់គ្លេស **I.B.E** ។ វិទ្យាស្ថាននេះមានទីតាំងស្ថិតនៅអគារលេខ៣១៥ផ្លូវហ្សាលដឺហ្គូល សង្កាត់អូឫស្សី២ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ២ : វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ មានមហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម និងមហាវិទ្យាល័យ ភាសា ធ្វើការបណ្តុះបណ្តាលចាប់ពីកម្រិត វិញ្ញាបនបត្រ វិញ្ញាបនប័ត្រជាន់ខ្ពស់រយៈពេលខ្លី បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។

មាត្រា ៣ : ក្នុងរយៈពេលបីខែបន្ទាប់ពីថ្ងៃចាប់ដំណើរការ វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ត្រូវរៀបចំ កម្មវិធីសិក្សាលំអិតតាមក្រេឌីត និងមុខជំនាញ ដើម្បីសុំការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា។ ចំពោះការប្តូរឈ្មោះ ការប្តូរទីតាំង ការពង្រីកទីតាំង ការបើកសាខា មហាវិទ្យាល័យ មុខជំនាញ ឬ ការធ្វើសហប្រតិបត្តិការជាមួយ គ្រឹះស្ថានឧត្តមសិក្សាបរទេស ត្រូវមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៤ : វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសំរេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំង និងការប្រព្រឹត្តទៅ របស់វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ត្រូវអនុវត្តតាមការណែនាំ និងបទដ្ឋាន ដែលពាក់ព័ន្ធនឹង ការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាលសំដៅធានាគុណភាព អប់រំ។

មាត្រា ៦ : នាយក វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ មានភារកិច្ចទទួលខុសត្រូវ នៅចំពោះមុខច្បាប់ក្នុង ការគ្រប់គ្រងវិទ្យាស្ថាន ធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូនក្រសួងអប់រំ យុវជន និងកីឡា តាមកំណត់។

មាត្រា ៧ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រនិងទទួលបានជោគជ័យក្នុងការប្រលង បញ្ចប់ការសិក្សាត្រូវទទួលសញ្ញាប័ត្រតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយ វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋានអង្គភាពពាក់ព័ន្ធ វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ម៉ិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៧០៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ និង កងកំលាំងប្រដាប់អាវុធ ចំនួន ៩៩ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-លោកឧត្តមសេនីយ៍ត្រី	**ខាំ ផាយ**	មេបញ្ជាការរង យោធភូមិភាគទី១
២-លោកឧត្តមសេនីយ៍ត្រី	**ហេង ខាំវណ្ណ**	មេបញ្ជាការរង យោធភូមិភាគទី១
៣-លោកឧត្តមសេនីយ៍ត្រី	**ឯម ម៉ាំអ៊ូរី**	នាយករងខុទ្ទកាល័យ អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
៤-លោកឧត្តមសេនីយ៍ត្រី	**ឃួន អឿ**	មេបញ្ជាការរង យោធភូមិភាគពិសេស
៥-លោកឧត្តមសេនីយ៍ត្រី	**ប្រាក់ សយ**	មេបញ្ជាការរង យោធភូមិភាគពិសេស
៦-លោកឧត្តមសេនីយ៍ត្រី	**ប៉ែន ផលពិសិដ្ឋ**	នាយសេនាធិការរង បញ្ជាការដ្ឋានវិស្វកម្មអគ្គបញ្ជាការ
៧-លោកវរសេនីយ៍ឯក	**ឆាំ ហុង**	នាយសេនាធិការរង យោធភូមិភាគទី១
៨-លោកវរសេនីយ៍ឯក	**សំ យ៉ាំ**	នាយសេនាធិការរង យោធភូមិភាគទី១
៩-លោកវរសេនីយ៍ឯក	**តន ធីន**	នាយសេនាធិការរង យោធភូមិភាគទី១
១០-លោកវរសេនីយ៍ឯក	**ឌី ធិន**	នាយសេនាធិការរង យោធភូមិភាគទី១
១១-លោកវរសេនីយ៍ឯក	**សុខ សេន**	នាយសេនាធិការរង យោធភូមិភាគទី១
១២-លោកវរសេនីយ៍ឯក	**សោម សាមិត្ត**	នាយសេនាធិការរង យោធភូមិភាគទី១
១៣-លោកវរសេនីយ៍ឯក	**តុប ណោ**	នាយផ្នែកលេខាធិការដ្ឋាន យោធភូមិភាគទី១
១៤-លោកវរសេនីយ៍ឯក	**រម្យ ហាយ**	នាយការិយាល័យទី៤ យោធភូមិភាគទី១

១៥-លោកវរសេនីយ៍ឯក	ឈាន ឫទ្ធិ	នាយការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគទី១
១៦-លោកវរសេនីយ៍ឯក	ឈី សុរិទ្ធ	នាយកសាលា យោធភូមិភាគទី១
១៧-លោកវរសេនីយ៍ឯក	ខាំ ស៊ុក	មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ស្ទឹងត្រែង
១៨-លោកវរសេនីយ៍ឯក	ឡូន គឿន	ស្នងការនគរបាលខេត្តស្ទឹងត្រែង
១៩-លោកវរសេនីយ៍ឯក	ដួង ចោម	មេបញ្ជាការកងរាជអាវុធហត្ថ ខេត្តមណ្ឌលគិរី
២០-លោកវរសេនីយ៍ឯក	ឈឹម សំអាង	នាយរងសេនាធិការ យោធភូមិភាគពិសេស
២១-លោកវរសេនីយ៍ឯក	នៅ សារុធ	នាយរងសេនាធិការ យោធភូមិភាគពិសេស
២២-លោកវរសេនីយ៍ឯក	ម៉េត ចំនួណា	នាយរងសេនាធិការ យោធភូមិភាគពិសេស
២៣-លោកវរសេនីយ៍ឯក	ចេង ម៉ិនធឿន	នាយរងសេនាធិការ យោធភូមិភាគពិសេស
២៤-លោកវរសេនីយ៍ឯក	ឈុប វណ្ណៈ	នាយការិយាល័យទី១ យោធភូមិភាគពិសេស
២៥-លោកវរសេនីយ៍ឯក	និត្យ សារិទ្ធ	នាយការិយាល័យទី២ យោធភូមិភាគពិសេស
២៦-លោកវរសេនីយ៍ឯក	មាស រតនា	នាយការិយាល័យទី៥ យោធភូមិភាគពិសេស
២៧-លោកវរសេនីយ៍ឯក	ឌឹប អាត	នាយការិយាល័យហ្វឹកហ្វឺន យោធភូមិភាគពិសេស
២៨-លោកវរសេនីយ៍ទោ	កៅ ឆុន	នាយការិយាល័យអភិវឌ្ឍន៍ យោធភូមិភាគពិសេស
២៩-លោកវរសេនីយ៍ទោ	ឡេង គន្ធាវរិទ្ធ	នាយផ្នែកវិស្វកម្មយោធភូមិភាគពិសេស
៣០-លោកវរសេនីយ៍ទោ	ឆន សុគន្ធ	នាយកមន្ទីរពេទ្យ យោធភូមិភាគពិសេស
៣១-លោកវរសេនីយ៍ទោ	ខេង សារុន	នាយការិយាល័យទី២ យោធភូមិភាគទី១
៣២-លោកវរសេនីយ៍ទោ	ឯក ចេត្តនា	នាយការិយាល័យទី៣ យោធភូមិភាគទី១
៣៣-លោកវរសេនីយ៍ទោ	នី សុចត្តនា	នាយការិយាល័យទី៥ យោធភូមិភាគទី១
៣៤-លោកវរសេនីយ៍ទោ	អ៊ុន សួនឌីន	នាយផ្នែកសុខាភិបាល យោធភូមិភាគទី១
៣៥-លោកវរសេនីយ៍ទោ	ផន្ន សាលន់	មេបញ្ជាការវរសេនាធំលេខ ៤២ យោធភូមិភាគទី១
៣៦-លោកវរសេនីយ៍ទោ	ជ័យ សុខា	មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តស្ទឹងត្រែង
៣៧-លោកវរសេនីយ៍ទោ	សុខ ទុត្តា	មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តស្ទឹងត្រែង
៣៨-លោកវរសេនីយ៍ទោ	កង ហ៊ីម	នាយរងការិយាល័យហិរញ្ញវត្ថុ យោធភូមិភាគទី១
៣៩- លោកវរសេនីយ៍ទោ	ឡូន សារម	នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេង ក្រសួងការពារជាតិ
៤០- លោកវរសេនីយ៍ទោ	ឆាយ យ៉ាត	នាយរងការិយាល័យបង្គុប្រកព នាយកដ្ឋានប្រេង ក្រសួងការពារជាតិ
៤១- លោកវរសេនីយ៍ទោ	ឡុញ ប្លង់	នាយការិយាល័យបុគ្គលិក នាយកដ្ឋាននគរបាលអន្តោប្រវេសន៍
៤២- លោកវរសេនីយ៍ទោ	ឆាយ ម៉ិណ្ណា	នាយការិយាល័យ ច្រកទ្វារព្រំដែន នាយកដ្ឋាននគរបាលអន្តោប្រវេសន៍
៤៣-លោកវរសេនីយ៍ទោ	ម៉ក់ ពិតូ	នាយការិយាល័យអន្តរាគមន៍ ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ
៤៤-លោកវរសេនីយ៍ទោ	ជា ទ៉ាន់ថា	ជំនួយការមេបញ្ជាការ កងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន
៤៥-លោកវរសេនីយ៍ទោ	ឡិម ទុន្តីរិទ្ធ	ជំនួយការមេបញ្ជាការ កងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន
៤៦-លោកវរសេនីយ៍ទោ	ហ៊ង សុខសាន្ត	ជំនួយការមេបញ្ជាការ កងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន
៤៧-លោក	ឈឹម កន	អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ខេត្តកណ្តាល
៤៨-លោក	គង់ និត្យធា	អភិបាលរង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
៤៩-លោក	ឡូន វណ្ណា	ការិយាល័យទំនាក់ទំនងសភា និង អធិការកិច្ច ខេត្តស្ទឹងត្រែង
៥០-លោក	ឆាយ យារង	អនុប្រធានការិយាល័យលទ្ធកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី
៥១-លោក	នាក់ អ៊ឹម	ប្រធានស្នាក់ការពន្ធដារ ខណ្ឌមករា
៥២-លោក	ថោង សារភាន	ពន្ធដារ ខណ្ឌទួលគោក
៥៣-លោក	តូច សំបូរ	មន្ត្រីលទ្ធកម្ម ទីស្តីការគណៈរដ្ឋមន្ត្រី
៥៤-លោក	សេង សារី	ប្រធានគណនេយ្យសាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង
៥៥-លោក	ចន្ទ្យ ខាន់សារិទ្ធ	មន្ត្រីរាជការ

៥៥-លោក	**សាក់ សារិទ្ធ**	មន្ត្រីរាជការ
៥៦-លោក	**ឆៀម ថា**	មន្ត្រីរាជការ
៥៧-លោក	**ម៉ុល សារី**	នាយការិយាល័យសន្តិសុខ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៥៨-លោកវរសេនីយ៍ត្រី	**មៀច សាមុត**	មេបញ្ជាការវរសេនាតូចស៊ើបការណ៍ យោធភូមិភាគទី១
៥៩-លោកវរសេនីយ៍ត្រី	**ចន ចាយ**	នាយរងការិយាល័យទី១ យោធភូមិភាគទី១
៦០-លោកវរសេនីយ៍ត្រី	**សន ថាច**	នាយរងការិយាល័យទី៤ យោធភូមិភាគទី១
៦១-លោកវរសេនីយ៍ត្រី	**ពិន ឆាលី**	នាយរងការិយាល័យទី៤ យោធភូមិភាគទី១
៦២-លោកវរសេនីយ៍ត្រី	**សយ សុផានី**	នាយរងការិយាល័យទី៥ យោធភូមិភាគទី១
៦៣-លោកវរសេនីយ៍ត្រី	**ចាន់ វណ្ណា**	នាយរងការិយាល័យទី១ យោធភូមិភាគទី១
៦៤-លោកវរសេនីយ៍ត្រី	**ជុំ ម៉ាក់គៀង**	នាយរងការិយាល័យហ្វឹកហ្វឺន យោធភូមិភាគទី១
៦៥-លោកវរសេនីយ៍ត្រី	**កែវ សុវណ្ណ**	នាយផ្នែកបំភ័ន្តអក្ខរៈ យោធភូមិភាគទី១
៦៦-លោកវរសេនីយ៍ត្រី	**ឈឹម ឆេន**	នាយផ្នែកវិស្វកម្ម យោធភូមិភាគទី១
៦៧-លោកវរសេនីយ៍ត្រី	**អ៊ុំ តូច**	នាយរងការិយាល័យទី២ យោធភូមិភាគទី៤
៦៨-លោកវរសេនីយ៍ត្រី	**ឈូ គីមនី**	នាយប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៦៩-លោកវរសេនីយ៍ត្រី	**ថោង សុផាត**	នាយរងប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៧០-លោកអនុសេនីយ៍ឯក	**តាន់ សុខវិជ្ជា**	នាយរងប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៧១-លោកអនុសេនីយ៍ឯក	**យឹម សារ៉ាន់**	នាយរងប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៧២-លោកអនុសេនីយ៍ឯក	**សម្បត្តិ មុន្នីវត្ថ**	នាយរងប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៧៣-លោកអនុសេនីយ៍ឯក	**អៀ សុផល**	នាយរងប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៧៤-លោកអនុសេនីយ៍ឯក	**យិន ធារ៉ា**	នាយរងផ្នែក ប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៧៥-លោកអនុសេនីយ៍ឯក	**ឡាង ពៅ**	មេបញ្ជាការវរសេនាតូច ៤២៣ យោធភូមិភាគទី១
៧៦-លោកអនុសេនីយ៍ឯក	**ខៀវ យាន**	ជំនួយការព័ត៌មាន ការិយាល័យទី២ យោធភូមិភាគទី១
៧៧-លោកអនុសេនីយ៍ឯក	**វ៉ាន់ ពុទ្ធិរិទ្ធ**	ជំនួយការបុគ្គលិក ការិយាល័យទី១ យោធភូមិភាគទី១
៧៨-លោកអនុសេនីយ៍ឯក	**ហេង គុយ**	ជំនួយការព័ត៌មាន ការិយាល័យទី២ យោធភូមិភាគទី១
៧៩-លោកអនុសេនីយ៍ឯក	**តន ឆៃ**	ជំនួយការប្រតិបត្តិការសឹក ការិយាល័យទី៣ យោធភូមិភាគទី១
៨០-លោកអនុសេនីយ៍ឯក	**ពៅ ចាន់ថុល**	ជំនួយការបូកសរុប ការិយាល័យទី៣ យោធភូមិភាគទី១
៨១-លោកអនុសេនីយ៍ឯក	**ឯល ខួន**	ជំនួយការគោលនយោបាយ ការិយាល័យទី៥យោធភូមិភាគទី១
៨២-លោកអនុសេនីយ៍ឯក	**ជា សារិន**	ជំនួយការហិរញ្ញវត្ថុ លេខាធិការដ្ឋាន យោធភូមិភាគទី១
៨៣-លោកអនុសេនីយ៍ឯក	**ចាន់ លីម**	ជំនួយការចាត់ការទូទៅ លេខាធិការដ្ឋាន យោធភូមិភាគទី១
៨៤-លោកអនុសេនីយ៍ឯក	**ណាំ នី**	នាយករងមន្ទីរពេទ្យ យោធភូមិភាគទី១
៨៥-លោកអនុសេនីយ៍ឯក	**ម៊ុន ចន្ថា**	នាយរងប៉ុស្តិ នគរបាលស្រកទ្វារព្រំដែនអន្តរជាតិ ភ្នំដិន
៨៦-លោកអនុសេនីយ៍ឯក	**អេង ហ៊ី**	ជំនួយការមេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស
៨៧-លោកអនុសេនីយ៍ទោ	**យី រិទ្ធី**	នាយរងផ្នែក ប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៨៨-លោកអនុសេនីយ៍ទោ	**សុខ តា**	នាយរងផ្នែក ប៉ុស្តិនគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៨៩-លោកអនុសេនីយ៍ទោ	**សុខ សាន្ត**	នាយរងផ្នែក ប៉ុស្តិការិយាល័យទី៤ នាយកដ្ឋាននគរបាលអន្តោប្រវេសន៍
៩០-លោកអនុសេនីយ៍ទោ	**តាវ គារី**	ជំនួយការខុទ្ទកាល័យ កងរាជអាវុធហត្ថលើផ្ទៃប្រទេស
៩១-លោកអនុសេនីយ៍ទោ	**យ៉េត តុត**	នាយសេនាធិការវរសេនាតូចកាំភ្លើងធំ យោធភូមិភាគទី១
៩២-លោកអនុសេនីយ៍ទោ	**សំ គីមស្រី**	នាយរងផ្នែកហិរញ្ញវត្ថុ វរសេនាធំលេខ៤២យោធភូមិភាគទី១
៩៣-លោកអនុសេនីយ៍ទោ	**សួន លាង**	ជំនួយការការិយាល័យទី១ កងទ័ពជើងគោក
៩៤-លោកអនុសេនីយ៍ត្រី	**យៀង សូនី**	នាយសេនាធិការ វរសេនាតូចស៊ើបការណ៍ យោធភូមិភាគទី១

២៣- លោក ជា ឈឹមស្រ៊ុន ២៥- លោកតា សៀ្ញ ពិន

២៤-លោក ជា តារា ២៦- លោក ហម សុវណ្ណ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៣.០៩៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូននាយទាហាន និង សប្បុរសជន ចំនួន ២៩ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមកសាង សមិទ្ធផលនានា ក្នុងខេត្ត-ក្រុងមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ÷

១-ព្រះតេជគុណ	**ឆាយ សំណាង**	១៣-លោកវរសេនីយ៍ត្រី	**ផាត់ ចិន្តា**
២-ព្រះតេជគុណ	**អ៊ុក សារ៉េត**	១៤-លោកវរសេនីយ៍ត្រី	**ឆេព ម៉ារាញ**
៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ	**ព្រហ្ម មរណៈ**	១៥-លោកវរសេនីយ៍ត្រី	**ឡុង សារ៉ន**
៤-ឯកឧត្តម	**យិន សុវណ្ណនី**	១៦-លោកវរសេនីយ៍ត្រី	**សូរ ចាន់សារ៉េត**
៥-លោកវរសេនីយ៍ឯក	**សន សុផាត**	១៧-លោកវរសេនីយ៍ត្រី	**អាន ស្រេង**
៦-លោកវរសេនីយ៍ឯក	**វ៉ែន សាយ**	១៨-លោកអនុសេនីយ៍ឯក	**ខៃ ខែត្រ**
៧-លោកវរសេនីយ៍ឯក	**ឈុយ សម្បត្តិ**	១៩-លោកអនុសេនីយ៍ឯក	**ជាត់ គយណា**
៨-លោកវរសេនីយ៍ឯក	**សុខ រីនណា**	២០-លោក	**អ៊ុង ម៉េងឆុង**
៩-លោកវរសេនីយ៍ឯក	**ព្រាប សារុន**	២១-លោក	**ម៉ាង ឆៅយ**
១០-លោកវរសេនីយ៍ឯក	**យស ណាថ**	២២-លោក	**ឈុន ម៉េរ**
១១-លោកវរសេនីយ៍ឯក	**សំណិត ទៀន**	២៣-លោក	**លឹម អាង**
១២-លោកវរសេនីយ៍ទោ	**ជុំ សេដ្ឋា**	២៤-លោក	**ញឹប ផល្លី**

២៥-លោក	**ជា ឈឹមស្រុង**	២៨-លោក	**ទ៊ែត ឡៀង**
២៦-លោក	**ជា តារា**	២៩-លោកតា	**ស៊ឿ ពិន**
២៧-លោក	**ហម សុវណ្ណ**		

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់**មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម - អស់លោក ជាមន្ត្រីជាន់ខ្ពស់ នាយទាហាន នាយនគរបាល និង សប្បុរសជន ចំនួន ១៦ រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួនចូលរួមកសាងសមិទ្ធផលនានា ក្នុងខេត្ត-ក្រុងមួយចំនួន ក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

១- ឯកឧត្តម	**ឡុយ សុផាត**	អភិបាលខេត្តស្ទឹងត្រែង
២- ឯកឧត្តម	**អន ស៊ុំ**	អភិបាលខេត្តបន្ទាយមានជ័យ
៣- ឯកឧត្តម ឧត្តមសេនីយ៍ទោ	**ហួត ឈាង**	មេបញ្ជាការយោធភូមិភាគទី១
៤- ឯកឧត្តម ឧត្តមសេនីយ៍ទោ	**ព្រហ្ម ឌិន**	មេបញ្ជាការយោធភូមិភាគពិសេស
៥- លោកឧត្តមសេនីយ៍ត្រី	**ឃួន សាវ៉ុន**	មេបញ្ជាការរងយោធភូមិភាគពិសេស
៦- លោកឧត្តមសេនីយ៍ត្រី	**ពូ សាម៉ិតឌី**	មេបញ្ជាការយោធភូមិភាគពិសេស
៧- លោកឧត្តមសេនីយ៍ត្រី	**នាម អឿន**	មេបញ្ជាការរង និងជា នាយសេនាធិការយោធភូមិភាគទី១
៨- លោកឧត្តមសេនីយ៍ត្រី	**សុខ ភាព**	នាយករងទីចាត់ការការពារព្រំដែន អគ្គបញ្ជាការ និងជាប្រធានការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ

៩-លោកឧត្តមសេនីយ៍ត្រី	**សូរ ចាន់ហេង**	មេបញ្ជាការកងពលតូចថ្មើរជើងលេខ ៥១
១០-លោកវរសេនីយ៍ឯក	**ម៉ី សិទ្ធន**	មេបញ្ជាការរងកងពលតូចថ្មើរជើងលេខ ៥១
១១-លោកវរសេនីយ៍ឯក	**ជួន ស៊ាងហាក់**	ស្នងការនគរបាលខេត្តក្រចេះ
១២- លោក	**សុខ ធីថា**	សប្បុរសជន នៅខេត្តសៀមរាប
១៣- លោក	**ហ៊ុម ថៃ**	សប្បុរសជន នៅខេត្តសៀមរាប
១៤- លោក	**ឆរ ស៊ីវន្ថា**	សប្បុរសជន នៅខេត្តសៀមរាប
១៥- លោក	**អ៊ុំ តូច**	សប្បុរសជន នៅខេត្តសៀមរាប
១៦- លោក	**ជឹម ថេន**	សប្បុរសជន នៅខេត្តសៀមរាប

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ១១ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦៦ អនក.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន និងមន្ត្រី នៃធនាគារអភិវឌ្ឍន៍ឥស្លាម ពិភពលោក (IDB) ចំនួន ១៧រូប ដែលបានជួយឧបត្ថម្ភសាងសង់សាលារៀន នៅខេត្តកំពង់ចាម ចំនួន ០៥ខ្នង ខេត្តក្រចេះ ចំនួន ០២ខ្នង និងនៅខេត្តកំពត ចំនួន០១ខ្នង ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ សរុបជាទឹកប្រាក់ទាំងអស់ចំនួន ៤០០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :-

១-លោក NABIL.H.ASHRI	អគ្គរាជទូតប្រទេសអារ៉ាប៊ីសេអ៊ូឌីត ប្រចាំទីក្រុងបាងកក
២-លោក Dr. AHMAD MOHAMED ALI	ប្រធានធនាគារ IDB
៣-លោក Dr. SYED JAAFAR AZNAN	អនុប្រធានធនាគារ IDB ទទួលបន្ទុកពាណិជ្ជកម្ម និង គោលនយោបាយ
៤-លោក MUZAFAR AL HAJ MUZAFAR	អនុប្រធានធនាគារ IDB ទទួលបន្ទុកធនធានសាជីវកម្ម និងសេវាកម្ម
៥-លោក Dr. AMADOU BOUBACAR CISSE	អនុប្រធាន ទទួលបន្ទុកខាងប្រតិបត្តិការ
៦-លោក ENG ABDUL RAHMAN AL AJMI	ជំនួយការពិសេសប្រធានសំរាប់បែងចែកជំនួយ និង អាហារូបករណ៍
៧-លោក Dr.MOHAMMAD HASSAN SALEM	ប្រធានផ្នែកជំនួយ
៨-លោក HASSAN JABER K.AL JEHANI	មន្ត្រីផ្នែកជំនួយ

១០-លោក FAHAD AL SHAMIRY	ប្រធានអង្គការសម្របសម្រួលជំនួយ ប្រទេសកូវ៉ែត ប្រចាំតំបន់អាស៊ីអាគ្នេយ៍
១១-លោក ENG EZZAT HASSANE AL SALAMUNI	តំណាងអង្គការសម្របសម្រួល ជំនួយ ប្រទេសកូវ៉ែត ប្រចាំប្រទេសថៃ
១២-លោក YOUSOF ALHAJJI	ប្រធានអង្គការមនុស្សធម៌ ឥស្លាមពិភព-លោកនៃប្រទេសកូវ៉ែត
១៣-លោក SALMAN JASEM AL BAHR	សប្បុរសជន នៃប្រទេសកាតា
១៤-លោក FARAJ AL NAIMI	សប្បុរសជន នៃប្រទេសកាតា
១៥-លោក ABDULLAH ALI ZEN	សប្បុរសជន នៃប្រទេសកាតា
១៦-លោក MURAQIBUTTAMKIN	អង្គការមនុស្សធម៌ ឥស្លាមពិភពលោក នៃប្រទេសកូវ៉ែត
១៧-លោក Dr.SALEH S. AL WOHAIBI	អគ្គលេខាធិការ អង្គការយុវជនឥស្លាម ពិភពលោក នៃប្រទេសអារ៉ាប៊ីសេអ៊ូឌីត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧១៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា១ : ត្រូវបានផ្ទេរភារកិច្ចជូនលោក **សរ សារមេធា** ពីប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល ទៅជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានផ្តល់ជំនួយជាសំភារៈឧបករណ៍ប្រើប្រាស់ សំរាប់មន្ទីរពេទ្យមួយចំនួនធំ ជូនដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ដូចមានរាយនាមខាងក្រោម :-

១-លោក **Dr. Hai Van Ha**

២-លោក **Vincent Tran**

៣-លោក **Tom Truong**

៤-លោក **Dr. Chau Van Nguuyen**

៥-លោកស្រី **Lou Bonary**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:១១៣៦...សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០៦

ប្រកាសណែនាំ
ស្តីពី
ការបិទបញ្ជីចំណូល-ចំណាយ និង
ការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិការដ្ឋឆ្នាំ២០០៦

- យោងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ ។

- យោងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ។

- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល ។

- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

- យោងអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីនីតិវិធីនៃការបើកផ្តល់មុនដោយអាណត្តិបើកប្រាក់សំរាប់ :

- ចំណាយដំណើរការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
- ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD) និង ចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ។

- យោងអនុក្រឹត្យលេខ ១៥៤ អនក្រ.បក.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០៦

- យោងអនុក្រឹត្យលេខ ១៥៥ អនក្រ.បក.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

ដោយឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ៤ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេស ដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយនិងការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋ ឆ្នាំ ២០០៦ ប្រព្រឹត្តទៅបានត្រឹមត្រូវ និង ទាន់ពេលវេលាដូចតទៅនេះ :

I- អំពីការបិទបញ្ជីចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៦

ក-អំពីចំណូលថវិការដ្ឋ

ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិយកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬ មួយពន្យាពេលបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ ណាមួយបានឡើយ (ភាគទី III និងមាត្រា១០៦ នៃ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ជាកំហិត ។**

ខ-អំពីចំណាយថវិការដ្ឋ

ការបិទបញ្ជីចំណាយ (មាត្រា ១០៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយនិងពេលវេលាដូចតទៅ :

* **ដិដ្ឋាការនៃការសន្យាចំណាយ** ក្រៅពីចំណាយបៀវត្ស និង ចំណាយសំរាប់គោលនយោបាយសង្គមកិច្ច **មិនអាចអនុវត្តក្រោយថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ បានទេ** (មាត្រា ១០៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥)។ ដូច្នេះគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវប្រញាប់ប្រញាល់រៀបចំបែបបទឯកសាររួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមបំណាច់ខែតុលា ឆ្នាំ ២០០៦ ដើម្បីទុករយៈពេល ១០ ថ្ងៃអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យ និង សំរេច ចុះទិដ្ឋាការធានាចំណាយជូនតាមការជាក់ស្តែង។ ក្នុងករណីមាន**ចំណាយចាំបាច់មិនអាចខានបាននិងមានឥណទានថវិកា សល់ទំនេរ** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងបន្តពិនិត្យធានាចំណាយជូន **តែក៏មិនឱ្យហួសពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៦ ដែរ** ហើយទិដ្ឋាការនេះត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (មាត្រា ២០ នៃអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។

* **រាល់ការសន្យាចំណាយដែលអាណត្តិបើកប្រាក់មិនបានធ្វើឡើងនៅមុនថ្ងៃទី ២៩ ខែ ធ្នូ នៃ ឆ្នាំ ២០០៦ ត្រូវបានបដិសេធចោល ហើយត្រូវសុំធ្វើការធានាចំណាយជាថ្មីដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់** (មាត្រា ១០៩ នៃ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។

* រតនាគារជាតិនិងរតនាគារខេត្ត-ក្រុង **ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦** លើកលែងអាណត្តិប្រាក់បៀវត្ស និង ប្រាក់គោលនយោបាយសង្គមកិច្ច និង

អាណត្តិនិយ័តកម្ម(មាត្រា១១ អនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ ដូច្នេះ ក្រសួង-ស្ថាប័នត្រូវប្រមូលសក្ខីប័ត្រនិងលិខិតយុត្តិការដែលបញ្ជាក់ពីសេវាដែលបានធ្វើរួចហើយ ដើម្បី **ធ្វើអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦** ។ ដោយឡែកមន្ទីរជំនាញខេត្ត-ក្រុង ត្រូវបញ្ជូនអាណត្តិបើកប្រាក់ដែលបានឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួចហើយ **ទៅអភិបាលខេត្ត-ក្រុងពិនិត្យចុះហត្ថលេខា ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦** ។

គ-<u>អំពីចំណាយរដ្ឋបេឡាបុរេប្រទាននិងថវិកាបុរេប្រទាន</u>

* **រដ្ឋបេឡាករបុរេប្រទាន** ត្រូវប្រមែប្រមូលលិខិតយុត្តិការចំណាយដើម្បីធ្វើអាណត្តិនិយ័តកម្ម (ទូទាត់) **យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ** ដោយគិតចាប់ពីកាលបរិច្ឆេទដកសាច់ប្រាក់ពីរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង (មាត្រា ៦៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) លើកលែងតែក្នុងខែធ្នូនៃឆ្នាំ រតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង ត្រូវ**បញ្ឈប់ការដកសាច់ប្រាក់ចុងក្រោយបង្អស់ពីគណនីរដ្ឋបេឡាបុរេប្រទាន នៅម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៦** ។ ក្នុងរយៈពេលពី**ថ្ងៃទី ១១ ដល់ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦** រដ្ឋបេឡាករបុរេប្រទានត្រូវរូតរះប្រមូលឯកសារ និង លិខិតយុត្តិការចំណាយ រួចធ្វើអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការ រួចបញ្ជូនទៅរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង **ត្រឹម ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦** ជាកំហិត ។

* **ថវិកាបុរេប្រទាន** គឺជាការបើកផ្តល់ចំណាយមុនដែរ ក្នុងករណីមានការចាំបាច់បន្ទាន់ ដូច្នេះការផ្តល់ថវិកាបុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ហើយការទូទាត់ថវិកាបុរេប្រទាននេះក៏ត្រូវរូតរះប្រមូលឯកសារសុំ**ទូទាត់ឱ្យបានមុនថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦** ដោយគិតរួមទាំងចំណាយថវិកាបុរេប្រទានជារូបិយប័ណ្ណអន្តរជាតិ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្តល់ជូនតាមរយៈមូលប្បទានប័ត្រ ។ **ក្នុងករណីប្រាក់បុរេប្រទានឆ្នាំ ២០០៦ ដែលមិនបានធ្វើការទូទាត់ឱ្យអស់នោះទេ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងកាត់ទុកឥណទានថវិកាពាក់ព័ន្ធក្នុងក្របខ័ណ្ឌថវិកាឆ្នាំ ២០០៧ មុននឹងធ្វើការធានាចំណាយ សំរាប់ឆ្នាំ ២០០៧** ។

ដោយឡែក ថវិកាបុរេប្រទានដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**បានបើកផ្តល់ជូនមុនបណ្តោះអាសន្នដោយអាណត្តិបើកប្រាក់**ជូនក្រសួង-ស្ថាប័ន **ដោយផ្អែកតាមអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០១** រដ្ឋបេឡាករនៃក្រសួង-ស្ថាប័ននេះ ត្រូវខិតខំប្រមូលឯកសារ និង លិខិតយុត្តិការចំណាយទាំងអស់តាមចំនួនទឹកប្រាក់ក្នុងអាណត្តិបើកប្រាក់និមួយៗ ដើម្បីត្រៀមរង់ចាំធ្វើសវនកម្មក្រោយចំណាយ។

ក្នុងករណីមានការខ្វះ ាតឥណទានថវិកាសំរាប់ធ្វើការទូទាត់រដ្ឋបេឡាបុរេប្រទាន ឬបុរេប្រទាន រដ្ឋបេឡាករត្រូវរាយការណ៍ជាបន្ទាន់ទៅអាណាប័ក ដើម្បីមានវិធានការតាមការជាក់ស្តែងជាអាទិ៍ :

- លើកសំណើសុំធ្វើនិយ័តភាពថវិកាផ្ទៃក្នុងដែលសល់ទំនេរមកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវធ្វើអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុនៗផងដែរ ។

- កាត់បន្ថយ ឬ ផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួនដែលមិនសូវចាំបាច់ សំដៅធ្វើការជំរះបញ្ជីចំណាយថវិកាបុរេប្រទាននេះឱ្យបានជ្រះស្រឡះ ។

ឃ-អំពីចលនាឥណទាន

ការធ្វើ**និយ័តភាពថវិកា**ផ្ទៃក្នុងជំពូកសំរាប់ការទូទាត់ចំណាយចាំបាច់ឬទូទាត់រដ្ឋទេយ្យបុរេប្រទាន ឬ ទូទាត់បុរេប្រទាន **ត្រូវបញ្ឈប់នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៦** ។ ដូច្នេះក្រសួង-ស្ថាប័ននិងមន្ទីរជំនាញតាមខេត្ត-ក្រុងទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំធ្វើនិយ័តភាពឥណទានមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរត្រឹមថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦** ។

ង-កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារ

កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវ**បន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧** (មាត្រា ១១១ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។ កិច្ចប្រតិបត្តិការនេះត្រូវពិនិត្យកត់ត្រាជាលេខនាបន្ថែម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលទាក់ទងទៅនឹង :

* ការកត់ត្រាជាស្ថាពរនៃចំណូល ឬចំណាយដែលបានពិនិត្យកត់ត្រាជាលេខនា មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។

* អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទាន និង បុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ។

* ការកែតម្រូវលេខនាខុស ។

* កិច្ចប្រតិបត្តិការប្រមូលកិច្ចការគណនេយ្យករនៃអង្គភាពរដ្ឋបាលហិរញ្ញវត្ថុ និង គណនេយ្យកររង នៃរតនាគារខេត្ត-ក្រុង ។

ច-កិច្ចប្រតិបត្តិការថវិកាឆ្នាំ ២០០៧

១- ក្នុងករណីមានភាពប្រញាប់លើឥណទាននៃឆ្នាំបន្ទាប់ (២០០៧) ក្នុងអំឡុងខែវិច្ឆិកា ឬ ខែធ្នូ ឆ្នាំ ២០០៦ អនុញ្ញាតអោយក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាលរៀបចំគំរោង និង ស្នើសុំធានាចំណាយថវិកា សំរាប់ឆ្នាំ ២០០៧ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាន ៥០% នៃកញ្ចប់ថវិកាឆ្នាំ ២០០៧ ដែលបានពិភាក្សា និង បានឯកភាពជាគោលការណ៍ក្នុងពេលការពារថវិកា ។

២- គំរោងស្នើសុំធានាចំណាយត្រូវធ្វើឡើងចំពោះតែមុខទំនិញ សេវា ឬ ការជួសជុលថែទាំទាំងឡាយណាដែលមានតំរូវការចំណាយថវិកាច្រើន និង មានតំរូវការជាបន្ទាន់នូវការផ្គត់ផ្គង់ទំនិញ សេវា ឬ ការជួសជុលថែទាំនៅដើមឆ្នាំ ២០០៧ ។

៣- ចំពោះការធានាចំណាយថវិកាជាបន្តបន្ទាប់ទៀត ដែលត្រូវអនុវត្តក្នុងកំឡុងឆ្នាំថវិកានឹងត្រូវផ្តល់ជូនក្រោយពីការតំរឹមផ្ទៀងផ្ទាត់ជាមួយឥណទានថវិកា ដែលត្រូវបានអនុម័តយល់ព្រមដោយអង្គការនីតិបញ្ញត្តិ ។

៤- ចាប់ពីថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០០៧** តទៅ រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋ ឆ្នាំថ្មី **ត្រូវកត់ត្រាចូលក្នុងគណនីថវិការដ្ឋឆ្នាំ ២០០៧** ។ដោយឡែកចំពោះប្រាក់បៀវត្សដែលនៅសល់ពីឆ្នាំចាស់ (២០០៦)

ហើយយកមកបង់ចូលក្នុង ឆ្នាំ ២០០៧ ត្រូវចាត់ទុកថាជាសំណេះចំណាយដោយកត់ត្រាបន្ថយលើខ្ទង់ចំណាយដែលមានការពាក់ព័ន្ធ ។

៥_ រាល់កិច្ចប្រតិបត្តិការចំណូល_ចំណាយថវិការដ្ឋឆ្នាំ ២០០៧ ត្រូវផ្អែកលើកម្មវិធីចំណូល_ចំណាយប្រចាំខែ និង ត្រីមាស ដែលក្រសួង_ស្ថាប័ន រដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត_ក្រុង ត្រូវរៀបចំ និង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ក្នុងរយៈពេល ០២ សប្តាហ៍ ក្រោយពីច្បាប់ថវិកាត្រូវបានអនុម័ត ។

II- **ការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល_ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៦**

ការបូកសរុបសម្រេចទូទាត់ថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៦ ត្រូវដំណើរការដូចតទៅ :

